ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

អគ្គនាយកដ្ឋានពន្ធដារ

លេខ...០៣៧.........អពដ

រាជធានីភ្នំពេញ ថ្ងៃទី០៤ ខែមករា ឆ្នាំ២០១៦

# សេចក្តីណែនាំ

## ស្តីពីការដាក់លិខិតប្រកាសនិងបង់ពន្ធប៉ាតង់ប្រចាំឆ្នាំ២០១៦

អនុលោមតាមបទប្បញ្ញត្តិនៃមាត្រា ១២ នៃច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៦ ដែលត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១២១៥/០១៦ ចុះថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១៥ និងប្រកាសលេខ ១៨២១ សហវ.ប្រក ចុះថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០១៥ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ស្តីពីវិធាននិងនីតិវិធីគ្រប់គ្រងប្រមូលពន្ធប៉ាតង់ អគ្គនាយកដ្ឋានពន្ធដារមានកិត្តិយសសូមធ្វើការណែនាំដល់សហគ្រាសដែលជាអ្នកជាប់ពន្ធតាមរបបស្វ័យប្រកាសទាំងអស់ មេត្តាជ្រាបអំពីកាតព្វកិច្ចដាក់លិខិតប្រកាសនិងបង់ពន្ធប៉ាតង់សម្រាប់ឆ្នាំ២០១៦ ដូចខាងក្រោម÷

១- អ្នកជាប់ពន្ធទាំងអស់ រួមទាំងអ្នកជាប់ពន្ធដែលមិនទាន់បានធ្វើបច្ចុប្បន្នភាព និងអ្នកជាប់ពន្ធដែលបានធ្វើបច្ចុប្បន្នភាពរួចរាល់ហើយ ត្រូវដាក់លិខិតប្រកាសនិងបង់ពន្ធប៉ាតង់ក្នុងអំឡុងពេលចាប់ពីថ្ងៃទី០១ ខែមករា ដល់ថ្ងៃទី៣១ ខែមីនា ឆ្នាំ២០១៦។

២- អ្នកជាប់ពន្ធធំអាចទៅបង់ពន្ធប៉ាតង់នៅនាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធធំ អ្នកជាប់ពន្ធមធ្យមនិងអ្នកជាប់ពន្ធតូចអាចទៅបង់ពន្ធប៉ាតង់នៅតាមសាខាពន្ធដារខេត្ត/ខណ្ឌ ដែលសហគ្រាសស្ថិតនៅ ឬនៅតាមសាខាធនាគារអេស៊ីលីដាភីអិលស៊ី ឬសាខាធនាគារកាណាឌីយ៉ា ក.អ ទូទាំងប្រទេស។

៣- ចំពោះអ្នកជាប់ពន្ធដែលបានធ្វើបច្ចុប្បន្នភាពនៃការចុះបញ្ជីដែលមានប័ណ្ណសម្គាល់ការចុះបញ្ជីពន្ធដាររួចហើយមិនតម្រូវឱ្យបំពេញលិខិតប្រកាសស្នើសុំបង់ពន្ធប៉ាតង់ទេ។ ប័ណ្ណប៉ាតង់ឆ្នាំ២០១៦នឹងត្រូវបានបោះពុម្ពប្រគល់ជូនអ្នកជាប់ពន្ធភ្លាមៗ ប្រសិនបើអ្នកជាប់ពន្ធទៅបង់ពន្ធនៅនាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធធំ ឬសាខាពន្ធដារខេត្ត/ខណ្ឌ ។ ចំពោះអ្នកជាប់ពន្ធដែលបង់ពន្ធនៅសាខាធនាគារទាំងពីរ ត្រូវបង្ហាញបង្កាន់ដៃបញ្ជាក់ពីការបង់ពន្ធ នៅអង្គភាពពន្ធដារដែលសហគ្រាសស្ថិតនៅ ដើម្បីទទួលបានប័ណ្ណប៉ាតង់។

៤- ចំពោះអ្នកជាប់ពន្ធដែលមិនទាន់ធ្វើបច្ចុប្បន្នភាពការចុះបញ្ជីពន្ធដារឬមិនទាន់ចុះបញ្ជីពន្ធដារ ត្រូវបំពេញលិខិតប្រកាសស្នើសុំបង់ពន្ធប៉ាតង់ទម្រង់ បព ០០៨/ Form PR 008 បន្ទាប់មកត្រូវទៅធ្វើបច្ចុប្បន្នភាពឬចុះបញ្ជីពន្ធដារនៅនាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធធំ សាខាពន្ធដារខេត្ត/ខណ្ឌ ឬក្រុមការងារចុះបញ្ជីពន្ធដារនៃអគ្គនាយកដ្ឋានពន្ធដារ នៅជាន់ទី០៦នៃអគារសាលាជាតិពន្ធដារ ទើបអាចទទួលបានប័ណ្ណប៉ាតង់ឆ្នាំ២០១៦នេះ។

៥- អ្នកជាប់ពន្ធដែលមានសកម្មភាពអាជីវកម្មច្រើនប្រភេទ ត្រូវបង់ពន្ធប៉ាតង់ផ្សេងគ្នាទៅតាមសកម្មភាពអាជីវកម្មនីមួយៗ។ សកម្មភាពជាឧបសម្ព័ន្ធនានានៃសកម្មភាពអាជីវកម្មត្រូវបានចាត់ទុកថាជាសកម្មភាពអាជីវកម្មតែមួយ។

Collection by VCAT Professional Consultant

អាគារកែងមហាវិថី សហព័ន្ធរុស្ស៊ី(១១០)និង ម៉ៅសេទុង(២៤៥) សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ (+855) 23 886 708 ទូរសារ: (+855)23 886 700, Email: gdt@tax.gov.kh, Website: www.tax.gov.kh

៦- អ្នកជាប់ពន្ធដែលមានសាខា ឃ្លាំង រោងចក្រ រោងជាង សម្រាប់សកម្មភាពអាជីវកម្មតែមួយក្នុងរាជធានី-ខេត្តតែមួយ ត្រូវបង់ពន្ធប៉ាតង់តែមួយ។ អ្នកជាប់ពន្ធដែលមានសកម្មភាពអាជីវកម្ម នៅក្នុងរាជធានី-ខេត្តផ្សេងគ្នា ត្រូវបង់ពន្ធប៉ាតង់ទៅតាមរាជធានី-ខេត្តដែលអាជីវកម្មនោះស្ថិតនៅ ។

៧- ប្រាក់ពន្ធប៉ាតង់ត្រូវបានកំណត់ដូចតទៅ÷

ក- **អ្នកជាប់ពន្ធធំ** ដែលមាននៅក្នុងបញ្ជីពន្ធដារបច្ចុប្បន្នដែលមាន÷

- ផលរបរ ១០ 000 000 000 រៀល ឬតិចជាង ត្រូវបង់ពន្ធប៉ាតង់ចំនួន ៣ 000 000 រៀល
- ផលរបរលើសពី ១០ 000 000 000 រៀល ត្រូវបង់ពន្ធប៉ាតង់ចំនួន ៥ 000 000 រៀល។

អ្នកជាប់ពន្ធធំដែលមានសាខា ឃ្លាំង រោងចក្រ រោងជាង សម្រាប់សកម្មភាពអាជីវកម្មតែមួយ ដែលស្ថិតនៅតាមរាជធានី-ខេត្តផ្សេងគ្នា ត្រូវបង់ពន្ធប៉ាតង់ចំនួន ៣ 000 000 រៀល។

ខ- **អ្នកជាប់ពន្ធមធ្យម** ដែលមានក្នុងបញ្ជីពន្ធដារបច្ចុប្បន្នត្រូវបង់ពន្ធប៉ាតង់ចំនួន ១ ២00 000 រៀល។

គ- **អ្នកជាប់ពន្ធតូច** ត្រូវបង់ពន្ធប៉ាតង់ចំនួន ៤00 000 រៀល។ អ្នកជាប់ពន្ធតូចគឺជាសហគ្រាសឯកបុគ្គល សហគ្រាសសហកម្មសិទ្ធិ ឬអ្នកជាប់ពន្ធដែលមានក្នុងបញ្ជីពន្ធដារតាមរបបម៉ៅការបច្ចុប្បន្នដែល÷

- មានផលរបរប្រចាំឆ្នាំ ចាប់ពី ២៥0 000 000 រៀល ដល់ ៧00 000 000 រៀល ឬ
- មានផលរបរក្នុងរយៈពេល ៣ ខែជាប់គ្នាកន្លងមក ចាប់ពី ៦0 000 000 រៀលឡើងទៅ ឬ
- រំពឹងថានឹងមានផលរបរក្នុងរយៈពេល ៣ ខែជាប់គ្នាខាងមុខ ចាប់ពី ៦0 000 000 រៀលឡើងទៅ
- ចូលរួមដេញថ្លៃ ពិគ្រោះថ្លៃ ឬស្នងថ្លៃក្នុងការផ្គត់ផ្គង់ទំនិញនិងសេវា រួមទាំងភាស៊ី

ចំនួនផលរបរខាងលើនេះ សំដៅដល់ផលរបរជាក់ស្តែងដែលបានមកពីការប្រកបអាជីវកម្ម មិនមែនជាផលរបរដែលបានកំណត់ក្នុងបញ្ជីពន្ធរបបម៉ៅការឡើយ។

៨- អ្នកជាប់ពន្ធត្រូវដាក់តាំងបង្ហាញប័ណ្ណប៉ាតង់ដែលមានសុពលភាព នៅទីតាំងប្រកបអាជីវកម្មរបស់ខ្លួន ហើយប័ណ្ណប៉ាតង់មានតម្លៃតែចំពោះអ្នកជាប់ពន្ធដែលមានឈ្មោះក្នុងប័ណ្ណប៉ាតង់តែប៉ុណ្ណោះ។ អគ្គនាយកដ្ឋានពន្ធដារមានវិធីគ្រប់គ្រងនិងបោះពុម្ពប័ណ្ណប៉ាតង់តាមប្រព័ន្ធអេឡិកត្រូនិក ដែលមិនអាចក្លែងបន្លំបានឡើយ។

៩- អ្នកជាប់ពន្ធត្រូវមានកាតព្វកិច្ចបង់ប្រាក់ពន្ធឱ្យបានត្រឹមត្រូវទៅតាមពេលវេលាដែលច្បាប់បានកំណត់។ ក្នុងករណីមិនបានបង់ ឬព្យាយាមបន្លំផលរបរដើម្បីគេចវេះពីការបង់ប្រាក់ពន្ធប៉ាតង់ ឬមានការក្លែងបន្លំប័ណ្ណប៉ាតង់ នឹងត្រូវទទួលរងទោសទណ្ឌដូចមានចែងក្នុងច្បាប់ស្តីពីសារពើពន្ធនិងបទប្បញ្ញត្តិស្តីពីពន្ធដារ។

អគ្គនាយកដ្ឋានពន្ធដារសង្ឃឹម និងជឿជាក់ថា សហគ្រាសដែលជាអ្នកជាប់ពន្ធតាមរបបស្វ័យប្រកាសទាំងអស់ ពិតជាយកចិត្តទុកដាក់អនុវត្តតាមខ្លឹមសារនៃសេចក្តីណែនាំនេះ។

**ប្រតិភូរាជរដ្ឋាភិបាល**

**ទទួលបន្ទុកជាអគ្គនាយក នៃអគ្គនាយកដ្ឋានពន្ធដារ**

**គង់ វិបុល**

Collection by VCAT Professional Consultant

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
MINISTRY OF ECONOMY AND FINANCE
អគ្គនាយកដ្ឋានពន្ធដារ
GENERAL DEPARTMENT OF TAXATION

ព្រះរាជាណាចក្រកម្ពុជា
KINGDOM OF CAMBODIA
ជាតិ សាសនា ព្រះមហាក្សត្រ
NATION RELIGION KING

**ទម្រង់ បព ០០៨ / FORM PR 008**

សម្រាប់បិទបាកូដ / Stick barcode here!

# លិខិតប្រកាសបង់ពន្ធប៉ាតង់ ប្រចាំឆ្នាំ
# PATENT TAX RETURN FOR YEAR

## ១. ខ្ញុំបាទ / នាងខ្ញុំស្នើសុំបង់ពន្ធប៉ាតង់ប្រចាំឆ្នាំ / I apply for whould like to patent tax for the year of Y Y Y Y

លេខអត្តសញ្ញាណកម្មសារពើពន្ធ
Tax Identification Number (TIN) _ _ _ _ - _ _ _ _ _ _ _ _ _

ឈ្មោះសហគ្រាស
Name of enterprise

ឈ្មោះសហគ្រាសជាអក្សរឡាតាំង
Name of enterprise in Latin

☐ នាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធធំ
Department of large tax payers

☐ សាខាពន្ធដារ
Tax branch

តើអាសយដ្ឋានទីចាត់ការសហគ្រាស ឬលេខទំនាក់ទំនងដូចព័ត៌មានបានចុះបញ្ជីពន្ធដារដែរឬទេ?
Is your head office address the same as when company register for the first time?

☐ ដូច Yes ▶ បើដូច សូមបំពេញចំណុចទី២ If Yes, please skip to section 2

☐ មិនដូច No ▶ បើមិនដូច សូមបំពេញព័ត៌មានបន្ថែមខាងក្រោម If No, please fill in information below

ផ្ទះលេខ/អគារ House Nº./Building | ផ្លូវ Street | ភូមិ Village

ឃុំ/សង្កាត់ Commune | ក្រុង/ស្រុក/ខណ្ឌ District / Khan | ខេត្ត/រាជធានី Province / Municipality

សារអេឡិកត្រូនិក Email | ប្រអប់សំបុត្រ/ប្រអប់សំបុត្រអេឡិកត្រូនិក P.O. Box / Electronic mail box

ទូរស័ព្ទចល័ត Mobile phone | ទូរស័ព្ទលើតុ Office telephone | ទូរសារ Fax

តើអចលនទ្រព្យដែលមានអាសយដ្ឋានខាងលើនេះជាកម្មសិទ្ធិរបស់អាជីវកម្មដ្ឋាន ឬជួល? Is the property of this above address owned by business or rented?

☐ កម្មសិទ្ធិ Owned — តើទីតាំងអាជីវកម្មនេះមានលេខអត្តសញ្ញាណកម្មអចលនទ្រព្យដែរឬទេ? Does this business location have property identification number (PIN) ? ☐ គ្មាន No ☐ មាន Yes

បើមាន សូមបំពេញលេខអត្តសញ្ញាណកម្មអចលនទ្រព្យ
If Yes, please fill in property identification number (PIN) ▶

☐ ជួល Rental — សូមបញ្ជាក់ថ្លៃឈ្នួលប្រចាំខែ Please state rental fee per month ៛

តើទីតាំងអាជីវកម្មនេះមានលេខអត្តសញ្ញាណកម្មអចលនទ្រព្យដែរឬទេ?
Does this business location have property identification number (PIN) ?

☐ គ្មាន No ☐ មាន Yes — សូមបំពេញលេខអត្តសញ្ញាណកម្មអចលនទ្រព្យ If Yes, please fill in property identification number (PIN) ▶

## ២. សកម្មភាពអាជីវកម្ម និងទឹកប្រាក់ពន្ធប៉ាតង់ / Business activities and amount of patent tax

| ល.រ No. | សកម្មភាពអាជីវកម្ម Business activities | ប្រាក់ពន្ធប៉ាតង់ត្រូវបង់ Patent tax payable |
|---|---|---|
| 1 | | ៛ |
| 2 | | ៛ |
| 3 | | ៛ |
| 4 | | ៛ |

▶ ក្នុងករណីមានសកម្មភាពអាជីវកម្មលើសពីបួន សូមបំពេញទម្រង់ បព ០០៨_០១ បន្ថែម
If business has more than 4 activities please fill additional form PR 008_01

| | | |
|---|---|---|
| **ប្រាក់ពន្ធប៉ាតង់សរុប** Sub total | 5 | ៛ |
| ប្រាក់ពន្ធបន្ថែមត្រូវបង់ Additional tax | 6 | ៛ |
| ការប្រាក់យឺតយ៉ាវ Interest | 7 | ៛ |
| **សរុប** (5+6+7) In total | 8 | ៛ |

ខ្ញុំបាទ/នាងខ្ញុំ សូមធានាថា រាល់ឯកសារ និងព័ត៌មានដែលបានបំពេញខាងលើ និងភ្ជាប់នៅក្នុងពាក្យស្នើសុំនេះពិតជាត្រឹមត្រូវ ប្រសិនបើមិនពិត ខ្ញុំបាទ/នាងខ្ញុំ សូមទទួលខុសត្រូវចំពោះមុខច្បាប់ជាធរមាន។ I declare that to the best of my knowledge information provided in this application form with all attachments is true and correct.

Collection by VCAT Professional Consultant

## សំណុំឯកសារភ្ជាប់ Attachment check-list

សម្គាល់៖ ចំពោះសំណុំឯកសារភ្ជាប់ទាំងអស់ ដែលជាច្បាប់ថតចម្លង ត្រូវមានការបញ្ជាក់ពីមន្ត្រីពន្ធដារមានសមត្ថកិច្ច ឬពីក្រសួង ស្ថាប័នពាក់ព័ន្ធ។
**Note :** All copied documnents attached must be certified by tax officials in charge or by other relevant ministries / institutions.

ករណីអាសយដ្ឋានទីចាត់ការសហគ្រាសខុសពីអាសយដ្ឋានពេលចុះបញ្ជី
If address of head office is different from registered address, please attach

1- ☐ ប័ណ្ណកម្មសិទ្ធិការកាន់កាប់ទីតាំង ឬកិច្ចសន្យាជួលទីតាំងប្រកបអាជីវកម្ម និងលិខិតប្រកាសពន្ធកាត់ទុកលើការជួលទីតាំង — ច្បាប់ថតចម្លង
Certificate of land title or rental contract and receipt of the withholding tax payment — Certified copy

2- ☐ លិខិតបញ្ជាក់ការបង់ប្រាក់ពន្ធអចលនទ្រព្យ ឬព័ត៌មានអចលនទ្រព្យ (ប្រសិនបើមាន) — ច្បាប់ថតចម្លង
Property tax receipt (If any) — Certified copy

កាលបរិច្ឆេទ / Date: ថ្ងៃ ខែ ឆ្នាំ

ហត្ថលេខា / Signature

ឈ្មោះ / Name

តួនាទី / Position

## សម្រាប់មន្ត្រីពន្ធដារ TAX OFFICIAL USE ONLY

1- ☐ បានពិនិត្យលិខិតប្រកាសដែលបានបំពេញបានត្រឹមត្រូវ និងទទួលបានឯកសារគ្រប់គ្រាន់
Application form and all attachments are already checked and verified.

2- ☐

| | |
|---|---|
| ប្រាក់ពន្ធប៉ាតង់ដែលត្រូវបង់សរុប<br>Total patent tax to be paid | ៛ |
| លេខគណនីធនាគារត្រូវបង់ចូល<br>Bank account number | |
| ឈ្មោះធនាគារ<br>Bank name | |
| លេខបង្កាន់ដៃបញ្ជាក់ការបង់ពន្ធ<br>Receipt Nº | |

សម្រាប់មន្ត្រី / For official

កាលបរិច្ឆេទ / Date: ថ្ងៃ ខែ ឆ្នាំ

យោបល់ផ្សេងៗ / Comments

ហត្ថលេខា Signature

សម្រាប់មន្ត្រីពិនិត្យឯកសារ / For supervisor

កាលបរិច្ឆេទ / Date: ថ្ងៃ ខែ ឆ្នាំ

យោបល់ផ្សេងៗ / Comments

ហត្ថលេខា Signature

ឈ្មោះមន្ត្រីទទួលបន្ទុក / Tax official in charge

លេខសម្គាល់មន្ត្រី / ID number

ឈ្មោះមន្ត្រីពន្ធដារ / Tax official

លេខសម្គាល់មន្ត្រី / ID number

Collection by VCAT Professional Consultant

**ទម្រង់ បព ០០៨_១ / FORM PR 008_1**

# ព័ត៌មានបន្ថែមសកម្មភាពអាជីវកម្ម
## ADDITTIONAL BUSINESS ACTIVITIES

| | |
|---|---|
| លេខអត្តសញ្ញាណកម្មសារពើពន្ធ<br>Tax Identification Number (TIN) | - |
| ឈ្មោះសហគ្រាស<br>Name of enterprise | |
| ឈ្មោះសហគ្រាសជាអក្សរឡាតាំង<br>Name of centerprise in Latin | |

**សកម្មភាពអាជីវកម្ម និងចំនួនប្រាក់ពន្ធប៉ាតង់ / Business activities and amount of patent tax**

| ល.រ<br>No. | សកម្មភាពអាជីវកម្ម<br>Business activities | ប្រាក់ពន្ធប៉ាតង់ត្រូវបង់<br>Patent tax payable |
|---|---|---|
| 1 | | ៛ |
| 2 | | ៛ |
| 3 | | ៛ |
| 4 | | ៛ |
| 5 | | ៛ |
| 6 | | ៛ |
| 7 | | ៛ |
| 8 | | ៛ |
| 9 | | ៛ |
| 10 | | ៛ |
| 11 | | ៛ |
| 12 | | ៛ |
| | សរុប<br>Total | ៛ |

| | |
|---|---|
| កាលបរិច្ឆេទ<br>Date | ថ្ងៃ / ខែ / ឆ្នាំ |
| ហត្ថលេខា<br>Signature | |
| ឈ្មោះ<br>Name | |
| តួនាទី<br>Position | |

Collection by VCAT Professional Consultant